# ទីស្ដីការរដ្ឋមន្ត្រី ក្រសួងដឹកជញ្ជូន

## ប្រកាស

ភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

## ប្រកាសលេខ ១៤៥ ប្រក ដជកពយ

## ស្ដីពីការបំពេញបន្ថែមចរាចរណ៍ណែនាំ

## លើការងារគ្រប់គ្រងមធ្យោបាយដឹកជញ្ជូន

## តាមផ្លូវគោក និងផ្លូវទឹក ក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសរួមលេខ ៣០២ ប្រ.កត.រចត ចុះថ្ងៃទី ១៤ ខែ ៩ ឆ្នាំ ១៩៩៣ ស្ដីពីការបែងចែកអង្គភាព ជូនក្រសួងសាធារណការនិងក្រសួងដឹកជញ្ជូន
- យោងសារាចររួម ក្រសួងដឹកជញ្ជូន ក្រសួងហិរញ្ញវត្ថុ លេខ ៣៣១ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣

## សំរេច

**ប្រការ ១ :** បំពេញបន្ថែមសារាចរណែនាំ លេខ ០០២ សរណន គមតពយ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៨៩ ត្រង់ជំពូកទី ១ និង ៦ " រូបភាពនៃផ្លាកលេខ " ។

**ប្រការ ២ :** នៅត្រង់ចំណុចទី ៦ ត្រូវបន្ថែម ៧ ផ្លាកលេខ " សាកល្បង " ។

**ប្រការ ៣ :** ផ្លាកលេខ " សាកល្បង " គឺជាផ្លាកលេខដែលម្ចាស់ហាងលក់យានយន្ត ត្រូវផ្ដល់អោយអ្នកទិញយានយន្ត ដើម្បីប្រើប្រាស់បណ្ដោះអាសន្ន ។ ផ្លាកលេខ " សាកល្បង " សំរាប់ទោចក្រយានយន្តនិងសំរាប់រថយន្ត ត្រូវយកទំហំដូចផ្លាកលេខដែលក្រសួងបានកំណត់រួចហើយ និងត្រូវមានលេខសំគាល់របស់ហាងលក់យានយន្ត ដាក់នៅពីក្រោមអក្សរ " សាកល្បង " ចំពោះផ្លាកក្រោយ និងមានលេខសំគាល់នៅពីក្រោយអក្សរ " សាកល្បង " ចំពោះផ្លាកមុខ ។

| សាកល្បង ០១ |
|---|

ផ្លាកលេខ មុខ

| សាកល្បង ០១ |
|---|

ផ្លាកលេខក្រោយ

ដើម្បីមានការងាយស្រួលដល់ភ្នាក់ងារមានសមត្ថកិច្ច ក្នុងការតាមដាននិងស្រាវជ្រាវក្នុងករណី យានយន្ត ពាក់ផ្លាកលេខ " សាកល្បង " បង្កអោយមានគ្រោះថ្នាក់ផ្សេងៗនោះ ជារៀងរាល់ថ្ងៃ ម្ចាស់ហាងត្រូវកត់ត្រានៅក្នុង សៀវភៅទិនានុប្បវត្តិ មួយ ( le journal ) នៅចំណុចសំខាន់ៗដូចតទៅ : លេខរៀង

ថ្ងៃ ខែ ឆ្នាំ ម៉ាកយានយន្ត លេខតួនិងលេខម៉ាស៊ីន ឈ្មោះនិងអសយដ្ឋានរបស់អ្នកទិញ ។ សៀវភៅកត់ត្រានេះត្រូវមាន ១០០ ទំព័រ និងត្រូវបោះត្រារបស់ក្រសួងដឹកជញ្ជូន នៅគ្រប់ទំព័រទាំងអស់ និងហាមមិនអោយរហែក ឬបាត់មួយសន្លឹកណាឡើយ ។

ក្នុងករណីដែលហាងលក់យានយន្ត គ្មានសាខានៅឡើយខេត្ត ក្រុ ..ទនោះ ម្ចាស់ហាងត្រូវផ្តល់ជូនគ្រប់មន្ទីរ គមនាគមន៍ខេត្តក្រុងនូវ :

- ឈ្មោះអាសយដ្ឋានរបស់ម្ចាស់ហាង
- យីហោឬសញ្ញាសំគាល់របស់ហ...
- ឈ្មោះអាសយដ្ឋាន គំរូហត្ថលេខា ( spécimen ) អ្នកដែលមានសិទ្ធចុះហត្ថលេខា នៅលើវិក័យប័ត្រ
- លិខិតអនុញ្ញាតិអោយធ្វើអាជីវកម្មលក់យានយន្ត ។ បើជាលិខិតចតចំលង ត្រូវមានសេចក្តីបញ្ជាក់របស់សាលាក្រុងថា "បានចំលងត្រឹមត្រូវតាមច្បាប់ដើម " ។

ប្រជាជនដែលមានទីលំនៅ នៅខេត្តក្រុងហើយមកទិញយានយន្តពីទីក្រុងភ្នំពេញ អាចទៅទាក់ទង មន្ទីរគមនាគមន៍ខេត្ត ក្រុង ដើម្បីស្នើសុំប័ណ្ណសំគាល់យានយន្តដោយខ្លួនឯងបាន ។

ក្នុងការផ្តល់ប័ណ្ណសំគាល់យានយន្ត មន្ទីរគមនាគមន៍ខេត្តក្រុងត្រូវ :

- ពិនិត្យវិក័យប័ត្រដោយផ្ទៀងផ្ទាត់ជាមួយ និងចំណុចផ្សេងៗ ដែលម្ចាស់ហាងផ្ញើមក ។
- ពិនិត្យអាស័យដ្ឋានរបស់យានយន្តអោយបានហ្មត់ចត់
- ពិនិត្យលិខិតពន្ធតើមានសេចក្តីបញ្ជាក់របស់ភ្នាក់ងារគយ និងប្រៃសណីយ៍ហើយឬនៅ ?

មន្ទីរគមនាគមន៍ខេត្ត ក្រុងមិនត្រូវផ្តល់ប័ណ្ណសំគាល់ណា ដែលគ្មានវិក័យប័ត្រឃ្លាំងនិងលិខិតពន្ធ ដែលគ្មានសេចក្តីបញ្ជាក់ របស់គយប្រៃសណីយ៍ឡើយ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ ពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន
ហត្ថលេខានិងត្រា
**សូ យុន**

******

ភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

## ឆីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម

# ប្រកាស

## ប្រកាសលេខ ២៩៦ ឧក.ប្រក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

- យោងព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូចនិងសិប្បកម្ម
- យោងលិខិតអនុញ្ញាតរបស់អភិបាលក្រុងភ្នំពេញ លេខ ២២៩ ៧ អ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩២